**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៧០/០០១/២០១០

ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១០

**សេចក្តីសម្រេច**

លេខ:១០៨/០០១/២០១០ កបធ.ច

ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១០

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៣៩ រស ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១០ របស់ឯកឧត្តម **ខួន ញឹល** ប្រធានរដ្ឋសភាស្តីទី ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីអស្សាមិករណ៏ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២នៃព្រឹទ្ធសភា នាថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១០ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១០ វេលាម៉ោង ០៩ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីអស្សាមិករណ៍
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ខ្លួន ញ៉ិល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីអស្សាមិករណ៍ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ច្បាប់ស្តីពីអស្សាមិករណ៍ ដែលមាន ៨ ជំពូក និង ៣៩ មាត្រា ក្នុងនោះ ៖

•មាត្រា ១ ចែងថា " ច្បាប់នេះ មានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធី នៃអស្សាមិករណ៍ និងសំណងឱ្យបានសមរម្យ និង យុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និង គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា ។ "

•មាត្រា ២ ចែងថា " ច្បាប់នេះមានគោលបំណងជាអាទិ៍ :

-ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និង យុត្តិធម៌

-ធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌

-បម្រើផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ

-ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។ "

មាត្រាទាំងពីរនេះ ស្របនឹងមាត្រា ៤៤ វាក្យខ័ណ្ឌទី២ និង ទី ៣នៃរដ្ឋធម្មនុញ្ញដែលចែងថា ៖

*" កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។ "*

*" ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌ ។ "*

ជាមួយគ្នានេះមាត្រា ៦១នៃរដ្ឋធម្មនុញ្ញ ចែងថា " *រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាល ដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និង មធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និង ប្រព័ន្ធឥណទាន* "

- យល់ឃើញថា ច្បាប់ស្តីពីអស្សាមិករណ៏បានធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធមិដូចមានបញ្ជាក់នៅក្នុង ÷

• មាត្រា ១៩ ដែលចែងថា " ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុអាចធ្វើទៅបាន លុះត្រាតែគណៈកម្មាធិការអស្សាមិករណ៏បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និង យុត្តិធមិ តាមគោលការណ៏ និង នីតិវិធីនៃការទូទាត់សំណង ... ។ "

• មាត្រា ២២ ដែលចែងថា " ប្រាក់សំណងដែលត្រូវផ្តល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិត្រូវគិតតាមថ្លៃទីផ្សារ ឬ ថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៏ ។

ថ្លៃទីផ្សារ ឬ ថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយតាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៏ ។ "

• មាត្រា ២៤ ដែលចែងថា " សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬ ជាសិទ្ធិជំនួស ទៅតាមភាពជាក់ស្តែង ដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ និង ពីគណៈកម្មាធិការអស្សាមិករណ៏ ... ។ "

- យល់ឃើញថា មាត្រា ៣៤ នៃច្បាប់ស្តីពីអស្សាមិករណ៏ ដែលចែងថា " ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាចប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៏ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៏សាធារណៈ ផលប្រយោជន៏ជាតិ និង ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យនិងយុត្តិធមិ ... " ស្របទៅនឹងមាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការ*

*រដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។"*

- យល់ឃើញថា ខ្លឹមសារនៅក្នុងមាត្រាទាំងអស់នៃច្បាប់ស្តីពីអស្សាមិករណ៍ ពុំមានបទប្បញ្ញត្តិណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ នៃព្រឹទ្ធសភា នាថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១០ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២ .-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**